ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៣២៨ សារ

សេចក្តីប្រកាសព័ត៌មាន
ស្តីពីការបន្តកាន់កាប់ដែនដីកម្ពុជា ឥនាសកម្មខាងស៊ីវិល និងវិបត្តិមនុស្សធម៌ ប្រព្រឹត្តដោយយោធាថៃ គិតត្រឹមថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៦

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ បានជ្រាបថា យោធាថៃ នៅតែបន្តកាន់កាប់ដែនដីផ្នែកខ្លះនៅតាមតំបន់ព្រំដែនកម្ពុជា និងថែមទាំងបានកំពុងបន្តប្រព្រឹត្ត សកម្មភាពល្មើសច្បាប់អន្តរជាតិជាច្រើនលើកច្រើនសារ លើដែនអធិបតេយ្យកម្ពុជា ដោយពុំបានចូលរួមអនុវត្តឱ្យ ពេញលេញតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) នោះឡើយ ជាពិសេស ការចាប់ផ្តើមពន្លឿនការវាស់វែង និងកំណត់ខណ្ឌសីមា ព្រមទាំងការជានាឱ្យពលរដ្ឋភៀសសឹកកម្ពុជា បានវិលចូលភូមិឋានរបស់ខ្លួនវិញ។ ក្រោយបទឈប់បាញ់ចូលជាធរមាន សកម្មភាពរបស់កាតីថៃជាបន្តបន្ទាប់ បានបង្កើតឱ្យមានវិបត្តិមនុស្សធម៌យ៉ាងធ្ងន់ធ្ងរលើប្រជាពលរដ្ឋស៊ីវិលកម្ពុជា បន្ទាប់ពីមានអ្នកបាត់បង់ជីវិត៣២នាក់ របួស៩៤នាក់ និងជាង៦០ម៉ឺននាក់ត្រូវប្រញាប់ភៀសខ្លួន ដើម្បីគេចចេញពីការចូលឈ្លានពានរបស់យោធាថៃ ដែលបានប្រើប្រាស់អាវុធគ្រប់ធុន និងគ្រប់ទម្រង់ ទាំងតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។

ស្របពេលជាមួយគ្នានេះ វិបត្តិមនុស្សធម៌ក៏បាននិងកំពុងកើតមានលើប្រជាជនកម្ពុជា ជាអាទិ៍ ក្នុងចំណោម ជនភៀសសឹកប្រមាណ ៦៤៩.០០០នាក់ អ្នកដែលបានវិលចូលទៅរស់នៅលំនៅឋានវិញ មានតែ៦២៥.០០០នាក់ ប៉ុណ្ណោះ ខណៈជាង២០.០០០នាក់ ទៀតបានកំពុងបន្តស្នាក់នៅតាមបណ្តាទីតាំង និងផ្ទះបណ្តោះអាសន្ន ដែលរៀបចំ ដោយរាជរដ្ឋាភិបាល ក្នុងនោះ នៅ**ខេត្តបន្ទាយមានជ័យ** មាន ៣.៣១៨ខ្នង **ខេត្តឧត្តរមានជ័យ** មាន៧៥៩ខ្នង **ខេត្តព្រះវិហារ** មាន៦៩១ខ្នង និង**ខេត្តពោធិ៍សាត់** មាន២៧ខ្នង ខណៈពលរដ្ឋខ្លះទៀតបន្តស្នាក់នៅតាមផ្ទះសាច់ញាតិ និងត្រូវបង្ខំចិត្តទៅរស់នៅ និងស្វែងរកការងារធ្វើនៅតាមបណ្តារាជធានី-ខេត្តផ្សេងៗជាបណ្តោះអាសន្ន។ បន្ថែមលើនេះ ទៀត កម្ពុជាក៏ទទួលរងនូវមហន្តរាយបង្កឡើងដោយការប្រើប្រាស់អាវុធហាមឃាត់ និងគ្រាប់យុទ្ធភណ្ឌពីយោធាថៃ ចូលតំបន់ស៊ីវិល និងទីតាំងវប្បធម៌ ពិសេសតំបន់បេតិកភណ្ឌពិភពលោក រួមមាន ការប្រើកាំភ្លើងធំធុនធ្ងន់ប្រភេទ ១៥៥មីលីម៉ែត្របាញ់គ្រាប់បែកចង្កោម (Cluster Munitions) ប្រមាណពី **១២ ទៅ ១៣ម៉ឺនគ្រាប់** មានបង្កប់ដោយកូន គ្រាប់មិនទាន់ផ្ទុះ ប្រមាណ **៦ ទៅ ៧លានគ្រាប់** ស្រោចលើតំបន់ស៊ីវិលទំហំជិត ៣.០០០គីឡូម៉ែត្រក្រឡា ក្នុងភូមិ យ៉ាងហោចណាស់៣៣៥ភូមិ ក្នុងចំណោម៣៤៩ភូមិដែលរងផលប៉ះពាល់។ ជាមួយគ្នានេះ **ប្រាសាទព្រះវិហារ** ប្រាសាទ តាមាន់ធំ តាមាន់តូច តាក្របី និងប្រាសាទខ្នារជាដើម ក៏រងការបាញ់បំផ្លាញយ៉ាងសន្ធាប់ ក្នុងនោះ តួប្រាសាទព្រះវិហារ រងការផ្លោង និងទម្លាក់គ្រាប់បំផ្លាញចំនួន៥០១គោលដៅ បង្កការខូចខាត ៥៦២កន្លែង ដោយមានផែនការយុទ្ធសាស្ត្រ យុទ្ធវិធី ការសម្របសម្រួល និងដឹកនាំបញ្ជាយ៉ាងច្បាស់លាស់ ក្នុងគោលបំណងកម្ទេចប្រាសាទតែម្តង។ អំពើ ឈ្លានពាននេះ បានបណ្តាលឱ្យមានផលប៉ះពាល់ផ្សេងៗទៀត ជាអាទិ៍ ផ្ទះ១.៥៥៨ខ្នង អគារស៊ីវិល៧ សណ្ឋាគារ/អគារ ស្នាក់នៅ១០ ស្ថានីយប្រេង៤ ផ្សារឯកជន១ រថយន្ត៣៤គ្រឿង បង្គោលអង់តែនទូរសព្ទ៣៩ ប្រព័ន្ធទឹកស្អាត៦ សាលារៀន២៦ មន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ អគាររដ្ឋបាល៧៤ វត្តអារាម១៩ ស្ពាន៥ ផ្លូវ៨៧ខ្សែ ផ្សារ១ បណ្តាញ បញ្ជូនអគ្គិសនី៣កន្លែង ព្រមទាំងទ្រព្យសម្បត្តិសាធារណៈ និងឯកជនជាច្រើនទៀត។

ជារួម អំពើឈ្លានពាន និងសកម្មភាពរបស់យោធាថៃខាងលើនេះ បានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាចំហ លើច្បាប់មនុស្សធម៌អន្តរជាតិ (IHL) អនុសញ្ញាគ្រាប់បែកចង្កោមនិងគ្រាប់មីនប្រឆាំងមនុស្ស និងគោលការណ៍ ហាមឃាត់ការវាយប្រហារដោយមិនរើសមុខលើតំបន់ស៊ីវិល រំលោភសិទ្ធិម្ចាស់កម្មសិទ្ធិ និងសិទ្ធិរស់នៅដូចមានចែង ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ឆ្នាំ១៩៤៨ និងអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការ ការពារសម្បត្តិវប្បធម៌ និងបេតិកភណ្ឌពិភពលោក ព្រមទាំងបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងសឺណែវ ឆ្នាំ១៩៤៩ ដែលហាមឃាត់ដាច់ខាតការបណ្តេញចេញ ការផ្ទេរដោយបង្ខំ និងការជម្លៀសជនស៊ីវិលពីទឹកដីដែលត្រូវកាន់កាប់ ដោយខុសច្បាប់ រួមទាំងសកម្មភាពនានាបង្កប់ចេតនារារាំងការវិលត្រឡប់ទៅវិញ។

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹង ចំពោះជំហរដ៏ម៉ឺងម៉ាត់ និង ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់យ៉ាងច្បាស់ថា ការចរចាបញ្ចប់សង្គ្រាម គឺជាការបញ្ចៀសបញ្ហាដោយសន្តិវិធី មិនអាចយកសង្គ្រាមទៅ បញ្ចប់សង្គ្រាមបានទេ។ ផ្ទុយទៅវិញ កម្ពុជាប្រកាន់ខ្ជាប់នូវការដោះស្រាយបញ្ហាព្រំដែន និងការទាមទារទឹកដី ដោយយកសមរភូមិការទូត និងសមរភូមិផ្លូវច្បាប់ជាមូលដ្ឋានដាច់ខាត ដើម្បីបញ្ចៀសការបាត់បង់អាយុជីវិតរបស់ កងទ័ព និងប្រជាពលរដ្ឋ ព្រមទាំងធានាការពារអធិបតេយ្យភាព និងបូរណភាពដែនដីជាតិឱ្យបានគង់វង្សស្ថិតស្ថេរ។ ក្នុងន័យនេះ យើងសូមអំពាវនាវដែនរួមជាតិ បន្តរក្សាស្មារតីរួបរួមសាមគ្គីជាតិ គាំទ្រនិងផ្តល់សេចក្តីទុកចិត្តជូនរាជរដ្ឋាភិបាល ដែលបានកំពុងខិតខំដោះស្រាយជម្លោះព្រំដែនជាមួយប្រទេសថៃប្រកបដោយភាពម៉ឺងម៉ាត់ និងសន្តិវិធី ឈរលើ កិច្ចព្រមព្រៀង សន្ធិសញ្ញា និងច្បាប់អន្តរជាតិ ព្រមទាំងរួមគ្នាទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយពីក្រុមប្រឆាំង បំផ្លាញផលប្រយោជន៍ជាតិ ដែលតែងតែបង្ហោះផ្សាយបំភ្លើស បំភ្លៃ ញុះញង់ និងបំផ្លាញកិច្ចខិតខំប្រឹងប្រែងរបស់ រាជរដ្ឋាភិបាល និងកិច្ចការពារបូរណភាពដែនដីដ៏អង់អាចក្លាហានរបស់វីរយុទ្ធជន៕

ថ្ងៃសៅរ៍ ១២រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៦